- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ ចាត់តាំងអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.តត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំងក្រសួងការពារជាតិ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ .- ត្រូវបានតម្លើងឋានន្តរសក្តិ និងតែងតាំងផ្លាស់ប្តូរមុខងារនាយទាហានក្នុងកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

ក-តែងតាំងមុខងារ

-លោក សស់ សាផន ធ្វើជាអ្នកជំនួយការសហរដ្ឋមន្ត្រីក្រសួងការពារជាតិ បច្ចុប្បន្នជា នាយក នាយកដ្ឋាននយោបាយផែនការ បន្ថែមលើមុខងារដែលមានស្រាប់

ខ-តម្លើងឋានន្តរសក្តិជាវរសេនីយឯក

១-វរសេនីយទោ ហង្ស មុណា អត្តលេខ ០០១៥៩២ នាយឃ្លាំងសព្វាវុធការ ៥ បច្ចុប្បន្នជា នាយករង នាយកដ្ឋានបច្ចេកទេស

២-វរសេនីយទោ អ៊ឹម សុផុន អត្តលេខ ០០០៥៧៦ នាយការិយាល័យកែសំភារៈ បច្ចុប្បន្នជា នាយការ នាយកដ្ឋានបច្ចេកទេស

៣-វរសេនីយទោ គង់ វ៉ាន់និទ្ធ អត្តលេខ ០០១៥៦៦ នាយការិយាល័យបច្ចេកទេស បច្ចុប្បន្នជា នាយករង នាយកដ្ឋានបច្ចេកទេស

៤-វរសេនីយទោ ហង្ស សំអន អត្តលេខ ០០០៥៧៤ នាយការិយាល័យបំពាក់ បច្ចុប្បន្នជា នាយក នាយកដ្ឋានបំពាក់

៥-វរសេនីយ៍ឯក ឆេត សាខន អត្តលេខ ០០០៥៧០ នាយការិយាល័យផលិតកម្ម បច្ចុប្បន្នជា នាយករង នាយកដ្ឋានបំពាក់

៦-វរសេនីយ៍ឯក ម៉ែន យន់ អត្តលេខ ០០១២១៥ នាយការិយាល័យរង់ចាំ បច្ចុប្បន្នជា នាយករង នាយកដ្ឋានបំពាក់

៧-វរសេនីយ៍ឯក សៀង ផលឈាង អត្តលេខ ០០០៥៦៥ នាយការិយាល័យគ្រប់គ្រងអង្គភាព បច្ចុប្បន្នជា នាយករង នាយកដ្ឋានហិរញ្ញវត្ថុ

៨-វរសេនីយ៍ឯក នាង ឆែន អត្តលេខ ០០០៦០១ នាយការិយាល័យផែនការ បច្ចុប្បន្នជា នាយករង នាយកដ្ឋានពលកម្ម

៩-វរសេនីយ៍ឯក គិន សេដ្ឋថុល អត្តលេខ ០០០៥៩៥ នាយការិយាល័យផែនការ បច្ចុប្បន្នជា នាយករង នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ

១០-វរសេនីយ៍ឯក ប្រាក់ ឌល្លី អត្តលេខ ០០២១០៥ នាយរងសេនាធិការបញ្ជាការដ្ឋានរថក្រោះ អគ្គសេនាធិការ បច្ចុប្បន្នជា មេបញ្ជាការរង និងជានាយសេនាធិការបញ្ជាការដ្ឋានរថក្រោះ អគ្គបញ្ជាការដ្ឋាន

១១-វរសេនីយ៍ឯក ម៉ា គិរម្យ អត្តលេខ ០០៣៥០៤ មេបញ្ជាការរង វរសេនាធំឆ័ត្រពិសេសកងទ័ពលេខ ៩១១ បច្ចុប្បន្នជា មេបញ្ជាការរង កងពលតូចឆ័ត្រពិសេសកងទ័ពលេខ ៩១១

១២-វរសេនីយ៍ឯក សុទ្ធ សារឿន អត្តលេខ ០០២១២៥ មេបញ្ជាការរង វរសេនាធំឆ័ត្រពិសេសកងទ័ពលេខ ៩១១ បច្ចុប្បន្នជា មេបញ្ជាការរង កងពលតូចឆ័ត្រពិសេសកងទ័ពលេខ ៩១១

១៣-វរសេនីយ៍ឯក មុំ សារម៉េត អត្តលេខ ០០០៧៧០ មេបញ្ជាការរង កងពលតូចឆ័ត្រលេខ ១ បច្ចុប្បន្នជា មេបញ្ជាការរង កងពលតូចឆ័ត្រពិសេសកងទ័ពលេខ ៩១១

១៤-វរសេនីយ៍ឯក នាក់ ស៊ីថាន់ អត្តលេខ ០០១២២៤ នាយសេនាធិការ កងពលតូចឆ័ត្រលេខ ១ បច្ចុប្បន្នជា មេបញ្ជាការរង កងពលតូចឆ័ត្រពិសេសកងទ័ពលេខ ៩១១

១៥-វរសេនីយ៍ឯក ម៉ៅ ទណ្ណៈ អត្តលេខ ០០២៤១៦ នាយសេនាធិការរង វរសេនាធំពិសេសកងទ័ពលេខ ៩១១ បច្ចុប្បន្នជា មេបញ្ជាការរង និងជានាយសេនាធិការ កងពលតូចឆ័ត្រពិសេសកងទ័ពលេខ ៩១១

១៦-វរសេនីយ៍ឯក កើត ណារិទ្ធ អត្តលេខ ០០០៨៩៥ មេបញ្ជាការរងកងពលតូចការពារអាកាស អគ្គសេនាធិការ បច្ចុប្បន្នជា មេបញ្ជាការរង បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការដ្ឋាន

១៧-វរសេនីយ៍ឯក ស៊ូ សារម៉េត អត្តលេខ ០០០៨៤២ មេបញ្ជាការរងកងពលតូចការពារអាកាស អគ្គសេនាធិការ បច្ចុប្បន្នជា មេបញ្ជាការរង បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការដ្ឋាន

១៨-វរសេនីយ៍ឯក សោម សំអាត អត្តលេខ ០០០៨៥៦ អនុប្រធាននាយកដ្ឋានបុគ្គលិកកងទ័ពអាកាស អគ្គសេនាធិការ បច្ចុប្បន្នជា អនុប្រធានរង បញ្ជាការដ្ឋានកងទ័ពអាកាស អគ្គបញ្ជាការដ្ឋាន

១៩-វរសេនីយ៍ឯក អឿ សំអុល អត្តលេខ ០០០៨៣២ អនុប្រធាននាយកដ្ឋានបុគ្គលិកកងទ័ពអាកាស អគ្គសេនាធិការ បច្ចុប្បន្នជា អនុប្រធានរង ពិសេសសេនាធិការ បញ្ជាការដ្ឋានកងទ័ពអាកាស អគ្គបញ្ជាការដ្ឋាន

២០-វរសេនីយ៍ឯក សំ សារិន អត្តលេខ ០០០៧៥៩ ប្រធានសេនាធិការរងបញ្ជាការដ្ឋានកាំភ្លើងធំ អគ្គសេនាធិការ បច្ចុប្បន្នជា អនុប្រធានរង ពិសេសប្រធានសេនាធិការ បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន

២១-វរសេនីយ៍ឯក ឆេង គឹមឈុន អត្តលេខ ០០០៧៨៥ នាយរង ក្រុមបញ្ជូនសារ អគ្គសេនាធិការ បច្ចុប្បន្នជា អនុប្រធានរង បញ្ជាការដ្ឋានបញ្ជូនសារ អគ្គបញ្ជាការដ្ឋាន

២២-វរសេនីយ៍ឯក ទង់ ធីរ៉ូ អត្តលេខ ០០១១៩៥ នាយការិយាល័យផ្គត់ផ្គង់ទីចាត់ការគមនាគមន៍ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយករង ទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការដ្ឋាន

២៣-វរសេនីយ៍ឯក ទេព សុវណ្ណ អត្តលេខ ០០១១២០ នាយកសេនាធិការ វរសេនាតូចល្បាតទ័ពជើងគោក លេខ ៩១១ បច្ចុប្បន្នជា នាយករង ទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការដ្ឋាន

២៤-វរសេនីយ៍ឯក ហឿង គីវឿន អត្តលេខ ០០២១៨៤ នាយរងក្រុមសុខាភិបាល អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង ទីចាត់ការសុខាភិបាល អគ្គបញ្ជាការដ្ឋាន

២៥-វរសេនីយ៍ឯក ឃៀង ទុន្នី អត្តលេខ ០០០៧៣៩ នាយរង ក្រុមសុខាភិបាល អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង ទីចាត់ការសុខាភិបាល អគ្គបញ្ជាការដ្ឋាន

២៦-វរសេនីយ៍ឯក មុន្នី ហោរ៉ាត់ អត្តលេខ ០០១៨៥៩ នាយកការិយាល័យប័ណ្ណអក្សរ អគ្គសេនាធិការ បច្ចុប្បន្នជា នាយករងទីចាត់ការប័ណ្ណអក្សរ អគ្គបញ្ជាការដ្ឋាន បន្ថែមលើមុខងារដែលមានស្រាប់

២៧-វរសេនីយ៍ឯក ខៀវ ឆេង អត្តលេខ ០០១៩៣២ នាយរង ក្រុមប័ណ្ណអក្សរ អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង ទីចាត់ការប័ណ្ណអក្សរ អគ្គបញ្ជាការដ្ឋាន

២៨-វរសេនីយ៍ឯក ខ្វាន់ ហាច អត្តលេខ ០០០៧៩២ នាយរង ក្រុមហិរញ្ញវត្ថុ អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន

២៩-វរសេនីយ៍ឯក គឹម គៀ អត្តលេខ ០០០៧៣៦ នាយរង ក្រុមផែនការ អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង ទីចាត់ការផែនការ អគ្គបញ្ជាការដ្ឋាន

៣០-វរសេនីយ៍ឯក អ៊ុច សំណាង អត្តលេខ ០០០៦៥៣ នាយរង ក្រុមផែនការ អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង ទីចាត់ការផែនការ អគ្គបញ្ជាការដ្ឋាន

៣១-វរសេនីយត្រី យឹម ផាន់ណាត អត្តលេខ ០០២១៣៦ នាយរង ក្រុមផែនការ អគ្គសេនាធិការ បច្ចុប្បន្ន ជា នាយករង ទីចាត់ការផែនការ អគ្គបញ្ជាការដ្ឋាន

៣២-វរសេនីយត្រី អ៊ុំ ឆាត អត្តលេខ ០០២២០០ នាយរង ក្រុមបច្ចេកទេស អគ្គសេនាធិការ បច្ចុប្បន្ន ជា នាយករង ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន

៣៣-វរសេនីយត្រី យូ សឿន អត្តលេខ ០០០៧៣១ នាយករង សាលាពហុជំនាញឯកទេស អគ្គសេនាធិការ បច្ចុប្បន្ន ជា នាយករង សាលាពហុជំនាញឯកទេសចំរុះ អគ្គបញ្ជាការដ្ឋាន

៣៤-វរសេនីយត្រី សុខ ខាន អត្តលេខ ០០០៧៣០ នាយករង សាលាពហុជំនាញឯកទេស អគ្គសេនាធិការ បច្ចុប្បន្ន ជា នាយករងសាលាពហុជំនាញឯកទេសចំរុះ អគ្គបញ្ជាការដ្ឋាន

៣៥-វរសេនីយត្រី ម៉ែន ស៊ីនតូ អត្តលេខ ០០០៩១២ នាយករង សាលាពហុជំនាញឯកទេស អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង សាលាពហុជំនាញឯកទេសចំរុះ អគ្គបញ្ជាការដ្ឋាន

៣៦-វរសេនីយត្រី ឃួន ឡិច អត្តលេខ ០០០៧៣៤ នាយរង ក្រុមបច្ចេកទេស អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង សាលាពហុជំនាញឯកទេសចំរុះ អគ្គបញ្ជាការដ្ឋាន

៣៧-វរសេនីយត្រី ឈឹម សាវុធ អត្តលេខ ០០១៩៤៨ នាយផ្នែកពិធីសាស្ត្រ ការិយាល័យទី ៣ អគ្គសេនាធិការ បច្ចុប្បន្នជា នាយករង ទីចាត់ការការពារពិធីសាស្ត្រ អគ្គបញ្ជាការដ្ឋាន

៣៨-វរសេនីយត្រី ខៀវ ទន អត្តលេខ ០០១៨៣៦ នាយផ្នែកបុគ្គលិក ការិយាល័យទី៣អគ្គសេនាធិការ បច្ចុប្បន្នជា នាយរង ខុទ្ទកាល័យ បញ្ជាការដ្ឋានកងទ័ពជើងគោក

៣៩-វរសេនីយត្រី រស់ វាសនា អត្តលេខ ០០១៨៥៧ លេខាផ្ទាល់ឯកឧត្តម អគ្គមេបញ្ជាការរង បច្ចុប្បន្នជា នាយរង ខុទ្ទកាល័យ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤០-វរសេនីយត្រី នុល ទិល អត្តលេខ ០០១៨៧១ នាយផ្នែកលេខាធិការដ្ឋានការិយាល័យទី១ អគ្គសេនាធិការ បច្ចុប្បន្នជា នាយរងការិយាល័យទី១ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤១-វរសេនីយត្រី ចាន់ សាវ៉ន អត្តលេខ ០០០៧៧៣ មេបញ្ជាការរង កងពលតូចទ័ពព្រៃ លេខ២១ បច្ចុប្បន្នជា នាយរង ការិយាល័យទី២ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤២-វរសេនីយត្រី សំ វណ្ណឌី អត្តលេខ ០០០៦៦៧ នាយផ្នែកសរុប ការិយាល័យទី៣ អគ្គសេនាធិការ បច្ចុប្បន្នជា នាយរង ការិយាល័យទី៣ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៣-វរសេនីយត្រី ឃុន ឆាងលី អត្តលេខ ០០០៩៦២ នាយរងផ្នែកប្រតិបត្តិការសឹកការិយាល័យទី៣ អគ្គសេនាធិការ បច្ចុប្បន្នជា នាយរង ការិយាល័យទី៣ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៤-វរសេនីយត្រី នឹម ស៊ឹម អត្តលេខ ០០០៦៧៦ នាយផ្នែកយោធបរិក្ខារការិយាល័យទី៤ អគ្គសេនាធិការ បច្ចុប្បន្នជា នាយរង ការិយាល័យទី៤ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៥-វរសេនីយ៍ឯក ស៊ិន ចាន់ អត្តលេខ ០០១៩០៥ នាយដ្ឋានបញ្ញា ការិយាល័យទី២ អគ្គសេនា
បច្ចុប្បន្នជា នាយរង ការិយាល័យទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៦-វរសេនីយ៍ឯក ជូ ជួន អត្តលេខ ០០១៨៣៩ មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គសេនា
បច្ចុប្បន្នជា នាយរង ការិយាល័យទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៧-វរសេនីយ៍ឯក សំ ទិន្នា អត្តលេខ ០០០៦៨២ នាយដ្ឋានបុគ្គលិក ការិយាល័យទី៥ អគ្គសេនា
បច្ចុប្បន្នជា នាយរង ការិយាល័យទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៨-វរសេនីយ៍ឯក ទិន សុវណ្ណារ៉ា អត្តលេខ ០០១៩៩៩ នាយដ្ឋានកិច្ចការក្រៅ ការិយាល័យទី៥
សេនាធិការ បច្ចុប្បន្នជា នាយរង ការិយាល័យទី៥ បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៩-វរសេនីយ៍ឯក អ៊ុក សារិន អត្តលេខ ០០០៦៩៥ នាយដ្ឋានប្រតិបត្តិការការិយាល័យកេតា
អគ្គសេនាធិការ បច្ចុប្បន្នជា នាយរង ការិយាល័យរោងចក្រដំណែបញ្ជាការដ្ឋានកងទ័ពជើងគោក

៥០-វរសេនីយ៍ឯក ឡឹម សារិទ្ធ អត្តលេខ ០០១១៩៩ នាយដ្ឋានភស្តុភារ ការិយាល័យទី៣ អគ្គសេ
ធិការ បច្ចុប្បន្នជា នាយរងការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានកងទ័ពជើងគោក

៥១-វរសេនីយ៍ឯក គង់ ម៉ក់ អត្តលេខ ០០០៧៥០ មេបញ្ជាការរង កងពលតូចលេខ១ កងវ
បច្ចុប្បន្នជា នាយរង ការិយាល័យវិស្វកម្ម បញ្ជាការដ្ឋានកងទ័ពជើងគោក

៥២-វរសេនីយ៍ឯក ម៉ែន ចំរើន អត្តលេខ ០០០៧៩៩ នាយសេនាធិការ កងពលតូចលេខ២ កងវ
បច្ចុប្បន្នជា នាយរង ការិយាល័យវិស្វកម្ម បញ្ជាការដ្ឋានកងទ័ពជើងគោក

៥៣-វរសេនីយ៍ឯក អ៊ុច វណ្ណារិទ្ធ អត្តលេខ ០០០៩៥៧ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកំ
បច្ចុប្បន្នជា មេបញ្ជាការ តំបន់ប្រតិបត្តិការសឹករងកំពត

ប្រការ ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោ
ធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

ហត្ថលេខា

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន ទៀ បាញ់

២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៩

សេចក្តីសំរេចលេខ ៦៧ សសរ

ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ បញ្ហាប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើ ការងារខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការ សំរាប់ដោះស្រាយបញ្ហាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើការងារខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី ដែលមានសមាសភាព ដូចខាងក្រោម ៖

១-ឯកឧត្តម នឹម ថូត រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ប្រធាន

២-ឯកឧត្តម សេង លីមនៅ អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន

៣-លោក ស៊ា កុសល ប្រធាននាយកដ្ឋានកុងស៊ុលនិងច្បាប់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៤-លោក ឌី សុខថាន អនុប្រធាននាយកដ្ឋាននយោបាយក្រសួងមហាផ្ទៃ សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ច ៖

-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរជាតិមានសមត្ថកិច្ច ដើម្បីរៀបចំទំរង់បែបបទនិងនីតិវិធី ដើម្បីការធ្វើមាតុភូមិនិវត្តន៍

-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរមានសមត្ថកិច្ចម៉ាឡេស៊ី ដើម្បីរកដំណោះស្រាយបញ្ហាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅ និងធ្វើការងារខុសច្បាប់នៅប្រទេសម៉ាឡេស៊ី

-ធ្វើរបាយការណ៍អំពីវឌ្ឍនភាពការងារ និងការត្រួតពិនិត្យនៃការអនុវត្តជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ ៖ សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងសាមីខ្លួន ដែលមានចែងឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

ភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

សេចក្តីសំរេចលេខ ៦៨ សសរ
ស្តីពីការ បើកថ្នាក់បរិញ្ញាបត្រគ្រប់មុខវិជ្ជាសិក្សា
តាមប្រព័ន្ធបង់ថ្លៃនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាបច្ចេកទេស
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

សំរេច

ប្រការ ១ ៖ អនុញ្ញាតអោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បើកថ្នាក់បរិញ្ញាបត្រ សិក្សាតាមប្រព័ន្ធបង់ថ្លៃចាប់ពីឆ្នាំសិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

ប្រការ ២ : ផ្នែកសិក្សាដែលត្រូវបើកមាន :

ក-មហាវិទ្យាល័យអក្សរសាស្ត្រ- មនុស្សសាស្ត្រ

-ផ្នែកអក្សរសាស្ត្រខ្មែរ ផ្នែកទស្សនវិជ្ជា

-ផ្នែកប្រវត្តិវិទ្យា ផ្នែកចិត្តវិទ្យា

-ផ្នែកសង្គមវិទ្យា ផ្នែកភូមិវិទ្យា

ខ-មហាវិទ្យាល័យវិទ្យាសាស្ត្រ

-ផ្នែកគណិតវិទ្យា ផ្នែកជីវវិទ្យា

-ផ្នែករូបវិទ្យា ផ្នែកពត៌មានវិទ្យា

-ផ្នែកគីមី ផ្នែកគ្រប់គ្រងធនធានធម្មជាតិ

គ-វិទ្យាស្ថានភាសាបរទេស

-ផ្នែកភាសាអង់គ្លេស និង វិជ្ជាជីវៈ

-ផ្នែកភាសាបារាំង និង វិជ្ជាជីវៈ

ប្រការ ៣ : លក្ខខណ្ឌចូលសិក្សា :

ជនគ្រប់រូបដែលមាន :

-សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតំលៃស្មើ ។

-បានប្រឡងជាប់ក្នុងការប្រឡងជ្រើសរើស

ប្រការ ៤ : ថ្នាក់បរិញ្ញាបត្រមានរយៈពេលសិក្សា ៤ ឆ្នាំ ។

- និស្សិតដែលបានរៀនមុខជំនាញរួចហើយ នៅតាមមហាវិទ្យាល័យឯកជននានាអាចផ្ទេរការសិក្សាចូលរៀនថ្នាក់បន្តនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងករណីមិនប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដែលគេមិនជឿទុកពីមុន ។
- ប្រព័ន្ធសិក្សាបង់ថ្លៃ និងប្រព័ន្ធសិក្សាឥតបង់ថ្លៃមិនអាចឆ្លងគ្នាទៅវិញទៅមកបានទេ ។
- ចុងឆមាសនៃឆ្នាំសិក្សានីមួយៗ និស្សិតត្រូវធ្វើការប្រឡងបញ្ចប់គ្រប់មុខវិជ្ជា ដែលមាននៅក្នុងកម្មវិធីប្រកបដោយជោគជ័យ ។

ប្រការ ៥ : ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតក្រុមប្រឹក្សាភិបាលមួយ ដើម្បីទទួលខុសត្រូវលើផ្នែកសិក្សា រដ្ឋបាល និង ហិរញ្ញវត្ថុ និងត្រូវធ្វើបទបញ្ជាផ្សេងៗ ដើម្បីគ្រប់គ្រងថ្នាក់ទាំងអស់នេះ អោយដំណើរការបានល្អ និងមានគុណភាព ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៨ : សេចក្តីសំរេចនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

សេចក្តីសំរេចលេខ ៦៩ សសរ

ស្តីពីការបង្កើតគណៈកម្មការដោះស្រាយបាតុភាពនៅក្នុងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងឧទ្យានជាតិកែប

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញសេចក្តីជូនដំណើងលេខ ១០៧៣ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញភាពចាំបាច់នៃការគ្រប់គ្រងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងកែប

សំរេច

ប្រការ ១ : តែងតាំងគណៈកម្មការដោះស្រាយបាតុភាពនៅក្នុងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និងក្រុងកែប ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ឆាន់ សាផាន រដ្ឋលេខាធិការក្រសួងបរិស្ថាន ជាប្រធាន

២-លោកឧត្តម ធឹក ឡៀនឧត្តា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន ជាអនុប្រធានប្រចាំការ

៣-លោកឧត្តម ម៉ុល សឹម អគ្គាធិការរងនៃអគ្គាធិការដ្ឋាន ក្រសួងមហាផ្ទៃ ជាអនុប្រធាន

៤-លោកឧត្តម ឈី ស៊ួ អភិបាល ខេត្តកំពត ជាអនុប្រធាន

៥-លោកឧត្តម ផាន ឆេ អភិបាលរងទី១ ក្រុងកែប ជាអនុប្រធាន

៦-លោកឧត្តម ឈឹម ជួន អភិបាលរងទី១ ខេត្តកំពត សមាជិក

៧-លោកឧត្តម ខៀវ មុត អគ្គនាយក ក្រសួងបរិស្ថាន សមាជិក

៨-លោកឧត្តម យ៉ា ឡេងហាន តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៩-លោកស្រី ខាយ សាមិទ្ធ ប្រធានលេខាធិការដ្ឋានគណៈកម្មាធិការជាតិ សមាជិក

១០-លោក លឹម ហោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក

១១-តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១២-តំណាង អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

១៣-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្មនិងសំណង់ខេត្តកំពត សមាជិក

១៤-ប្រធានមន្ទីរភូមិបាល ក្រុងកែប សមាជិក

១៥-ប្រធានមន្ទីរបរិស្ថានខេត្តកំពត សមាជិក

១៦-ប្រធានមន្ទីរបរិស្ថាន ក្រុងកែប សមាជិក

១៧-អភិបាលស្រុកកំពត សមាជិក

១៨-អភិបាលរងក្រុងកែប សមាជិក

១៩-នាយកឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " សមាជិក

ប្រការ ២ : ភារកិច្ចរបស់គណៈកម្មការ មាន :

- ចុះពិនិត្យដោះស្រាយបញ្ហាកាន់កាប់ដីធ្លីខុសច្បាប់នៅក្នុងតំបន់ឧទ្យានជាតិព្រះមុនីវង្ស " បូកគោ " និង ឧទ្យានជាតិកែប តាមស្មារតីនៃសេចក្ដីជូនដំណឹងលេខ : ១០៧៣ សជណ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៩ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។
- ធ្វើសេចក្ដីរាយការណ៍ និងលើកយោបល់ស្ដីពីវិធានការដោះស្រាយជូនឯកឧត្តមនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ។

ប្រការ ៣ : លេខាធិការដ្ឋានគណៈកម្មការ ដែលតាំងនៅក្រសួងបរិស្ថាន ស្ថិតនៅ ខេត្តកំពត ត្រូវទទួលខុសត្រូវក្នុង ការរៀបចំផែនការសកម្មភាព ភារកិច្ចដែលបានចែងក្នុងប្រការ ២ ខាងលើ និងត្រូវជួយសម្របសម្រួលតាមការណែនាំ របស់ប្រធានគណៈកម្មការ និងមានសិទ្ធិបង្កើតក្រុមមន្ត្រីជំនាញក្រុមការងារបច្ចេកទេសតាមការចាំបាច់ ។

ប្រការ ៤ : រាល់ការចំណាយ និងសម្ភារៈបរិក្ខារការងារ ត្រូវបើកពីកញ្ចប់ថវិកាជាតិ ។

ប្រការ ៥ : គណៈកម្មការមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

ប្រការ ៦ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងពាក់ព័ន្ធ អភិបាលខេត្តកំពតប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលក្រុងកែប ត្រូវអនុវត្តសេចក្តីសំរេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★

III- ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩៩

ប្រកាសលេខ ២១២ មន.ប្រក

ស្តីពីការបង្កើតគ្រូមការងារអន្តក្រសួង

***

រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញលិខិតលេខ ១២៨១ សជណ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញលិខិតលេខ ២១៣៦/៩៩ ក.អ.ក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៣៥០៦ សហវ.ខរ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញការចាំបាច់របស់ក្រសួង

សម្រេច

ប្រការ ១ : ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ។
ក្រុមការងារអន្តរក្រសួងនេះមានសមាសភាពដូចតទៅ :

១-ឯកឧត្តម **ផាន់ គិន** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធាន

២-ឯកឧត្តម **ឡាំ គួសាន** រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អនុប្រធាន

៣-ឯកឧត្តម **ង៉ុន ឈន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៤-ឯកឧត្តម **សួន សិទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា អនុប្រធាន

៥-ឯកឧត្តម **ឡូ ណារ៉ិត** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

៦-ឯកឧត្តម **នួយ គឹមស៊ា** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

៧-ឯកឧត្តម **ឡុង ទ៉ាន់ឃាន** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

៨-ឯកឧត្តម **សេ សម៉ៃ** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

៩-ឯកឧត្តម **ម៉ា សូផាន់ណា** អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក

១០-លោក **កាំង លាងខំណួ** អនុប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១-លោក ញាណ ស្រស់ ប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ សមាជិក

១២-លោក គុប សុខខួន ប្រធាននាយកដ្ឋាននយោបាយទូរគមនាគមន៍និយ័ត និងទំនាក់ទំនងអន្តរជាតិ សមាជិក

១៣-លោក លី សំអាន ប្រធាននាយកដ្ឋានទូរគមនាគមន៍ អន្តរជាតិ សមាជិក

១៤-លោក ឌុច ឃេង ប្រធាននាយកដ្ឋានទូរគមនាគមន៍ ក្នុងប្រទេស សមាជិក

១៥-លោក ស៊ា ណារ៉េត ប្រធាននាយកដ្ឋានរលកអាកាសវិទ្យុទូរគមនាគមន៍និងអាជ្ញាប័ណ្ណ សមាជិក

១៦-លោក ឈី សុខា អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ សមាជិក

១៧-លោក ទាំ ម៉ូឈឿន អនុប្រធាននាយកដ្ឋានប្រៃសណីយ៍ សមាជិក

១៨-កញ្ញា ឡេ ម៉ាយឡឿង អនុប្រធាននាយកដ្ឋានផែនការ ហិរញ្ញវត្ថុ សមាជិក

១៩-លោក គង់ សេង មន្ត្រីក្នុងខុទ្ទកាល័យរដ្ឋមន្ត្រី សមាជិក

ប្រការ ២ : ក្រុមការងារនេះមានភារកិច្ច :

១-សិក្សា និង ស្រាវជ្រាវលើការងារនានាក្នុងការអនុវត្តន៍ តាមការណែនាំរបស់រាជរដ្ឋាភិបា លេខ១១/សរណ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ និងលិខិតណែនាំស្តីពីសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ៣២៥០/សហវ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៩៩ និងលេខ ៣៥៥៩/សហវ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ ។

២-ក្រុមការងារនេះត្រូវរាយការណ៍លទ្ធផលការងារធ្វើជូនឯកឧត្តមរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីសុំយោបល់ ។

ប្រការ ៣ : ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សំរាប់ការងារនៃក្រុមការងារ ។

ប្រការ ៤ : សមាជិកក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

ប្រការ ៥ : រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ប្រៃសណីយ៍ និងទូរ

សូ ឃុន

***

២-នីតិការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩

ប្រកាសលេខ ៨៩២ អយក.ប្រក

ស្តីពីការបើក អនុវិទ្យាល័យ អន្លង់ស ក្នុង ឃុំ អន្លង់ស ស្រុក មេសាង ខេត្តព្រៃវែង

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសេចក្តីសម្រេចលេខ ៦៦ អវ.ចបអ ចុះថ្ងៃទី០២ មេសា ឆ្នាំ១៩៨៣ស្តីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១ កម្រិត២
- យោងលិខិតស្នើសុំរបស់ សហគមន៍ ហ៊ុនអង្គរតា ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត ព្រៃវែង
- តាមសេចក្តីចាំបាច់របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សម្រេច

ប្រការ ១ ៖ អនុញ្ញាតឱ្យបើកអនុវិទ្យាល័យថ្មីមួយមានឈ្មោះថា៖ អនុវិទ្យាល័យអង្គរតា ចាប់ពីឆ្នាំសិក្សា១៩៩៩-២០០០ តទៅ ។

ប្រការ ២ ៖ អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកម្នាក់ និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ ៖ នាយក នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ការងារតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ ៖ អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង និង នាយកអនុវិទ្យាល័យ សាមីមានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩

ប្រកាសលេខ ៨៩៣ អយក.ប្រក
ស្តីពីការបើក អនុវិទ្យាល័យ ស្រែពោធិ ក្នុង ឃុំ ស្រះឫស្សី ស្រុក ស្ទឹងត្រែង ខេត្តស្ទឹងត្រែង

***

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីក បង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តី ប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងក ប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អយ.សរណ ចុះថ្ងៃទី០២ មេសា ឆ្នាំ១៩៩៨ស្តីពីការបើ សាលារៀនមធ្យមសិក្សាកំរិត១ កំរិត២
- យោងលិខិតស្នើសុំរបស់ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្ទឹងត្រែង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីអភិបាលខេត្ត ស្ទឹងត្រែង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ ស្រែពោធិ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិក ផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអ

យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង និងលោកនាយកអនុវិទ្យាល័យ សាមីការតាមភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៩

ប្រកាសលេខ ៨៩៤ អយក.ប្រក

ស្តីពីការបើក អនុវិទ្យាល័យ ព្រៃឃ្លេស ក្នុង ឃុំ ព្រៃឃ្លេស ស្រុក មេសាង ខេត្តព្រៃវែង

***

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចបអ ចុះថ្ងៃទី០២ មេសា ឆ្នាំ១៩៨៣ស្តីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១ កម្រិត២
- យោងលិខិតស្នើសុំរបស់ សហគមន៍ ឃុំព្រៃឃ្លេស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៩ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា និងអភិបាលខេត្ត ព្រៃវែង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកអនុវិទ្យាល័យថ្មីដែលមានឈ្មោះថា : អនុវិទ្យាល័យ ព្រៃតបួស ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកម្នាក់ និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករងនៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំពេញការកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង និង នាយកអនុវិទ្យាល័យគោកពី មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

អ៊ឹម សិទ្ធី

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

ប្រកាសលេខ ៨៩៥ អយក.ប្រក

ស្តីពីការពង្រីក និងប្តូរឈ្មោះ អនុវិទ្យាល័យ សៀមរាប ទៅជាវិទ្យាល័យ ហ៊ុន សែន " ប្រាសាទបាគង " ស្ថិតនៅក្នុង ឃុំ បាគង ស្រុក ប្រាសាទបាគង ខេត្តសៀមរាប .

***

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ ឆ្នាំ

- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ មីនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសេចក្ដីសម្រេចលេខ ៦៦ អរ.ចបអ ចុះថ្ងៃទី០២ មេសា ឆ្នាំ១៩៩៣ស្ដីពីការបើកសាលាមធ្យមសិក្សាកំរិត១ កំរិត២
- យោងលិខិតស្នើសុំរបស់ អធិការអប់រំ យុវជន និង កីឡា ខេត្ត សៀមរាប ចុះថ្ងៃទី១២ ខែមករា ឆ្នាំ១៩៩៩ ដោយមានការយល់ព្រមពីអភិបាលខេត្ត សៀមរាប
- តាមសំណើរបស់លោកប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យតម្លើង និងប្ដូរឈ្មោះអនុវិទ្យាល័យសៀមរាប "[illegible]" ទៅជាវិទ្យាល័យ ហ៊ុន សែន "[illegible]" គិតពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវរៀបចំដោយអនុលោមតាមកម្មវិធី និងគោលការណ៍ណែនាំរបស់ក្រសួង ព្រមទាំងមន្ត្រីផ្សេងៗ ប្រព្រឹត្តទៅតាមអនុក្រឹត្យលេខ នៃវិទ្យាល័យ ។

ប្រការ ៣ : នាយក នាយករងនៃវិទ្យាល័យមានសិទ្ធិចូលប្រព្រឹត្តបំពេញភារកិច្ចតាមគោលការណ៍របស់ក្រសួង ។

ប្រការ ៤ : អគ្គនាយកបុគ្គលិក និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប និង នាយកវិទ្យាល័យ ត្រូវអនុវត្តតាមភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា
រដ្ឋលេខាធិការ
[illegible]
អ៊ឹម សិទ្ធី

★★★

៣-នីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៩

ប្រកាស

ប្រកាសលេខ ៧០៣ ធស.ប្រក

ស្ដីពីការតែងតាំងមន្ត្រីរាជការ

***

រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ដែលព្រះរាជាណាចក្រកម្ពុជាលេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញលិខិតលេខ ៨៨-៩៩ ធស.សអ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ របស់មន្ទីរធម្មការ និងសាសនា ក្រុងព្រះសីហនុ
- អនុលោមតាមការចាំបាច់របស់ក្រសួង និង តាមសមត្ថភាពរបស់មន្ត្រីរាជការ

សម្រេច

ប្រការ ១ : តែងតាំងលោក **សុខ ឡាង** បច្ចុប្បន្នប្រធានការិយាល័យធម្មការ ជា អនុប្រធានមន្ទីរធម្មការ និងសាសនាក្រុងព្រះសីហនុ ។

ប្រការ ២ : ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក **សុខ ឡាង** ត្រូវបើកជូនមន្ទីរធម្មការ និងសាសនាក្រុងព្រះសីហនុជាអ្នករៀបចំ និងកាន់កាប់ ។

ប្រការ ៣ : ខុទ្ទកាល័យ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុក្រុងព្រះសីហនុ និងលោក **សុខ ឡាង** ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ជា សាវឿន

★★★

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល